**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខៈ២៧២៨០ អយក.ហវ

ថ្ងៃសុក្រ ១០កើត ខែអាសាឍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២៥

**សូមគោរពជូន**
**ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**កម្មវត្ថុ** ៖ សំណើសុំអនុញ្ញាតជាគោលការណ៍ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៦ តទៅ។

**យោង** ៖ -អនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ របស់រាជរដ្ឋាភិបាលកម្ពុជា
-លិខិតលេខ៥៧៤៥ អយក.ហវ ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០២៤ របស់ក្រសួងអប់រំ យុវជន និងកីឡា
-សារាចរលេខ ០០១ សហវ.ស.រ.អថ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមគោរពជូន ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបថា៖ ក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៦ តទៅ ដើម្បីឱ្យស្របទៅនឹងរចនាសម្ព័ន្ធកម្មវិធីអាទិភាពក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ និងបន្សុំរចនាសម្ព័ន្ធការគ្រប់គ្រងរដ្ឋបាលនៃអនុក្រឹត្យលេខ១០១ អនក្រ.បក ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០២៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ទន្ទឹមនឹងនេះ ក្រសួងក៏បានសហការជាមួយមន្ត្រីបច្ចេកទេសរបស់អគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងពិភាក្សាជាច្រើនលើកច្រើនសារក្នុងការកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៦ ដោយផ្តល់ធាតុចូលជាច្រើនធ្វើយ៉ាងណាឱ្យគ្រប់ជ្រុងជ្រោយក្នុងការធានាប្រសិទ្ធភាពនៃការអនុវត្តឱ្យប្រកបដោយភាពច្បាស់លាស់និងចូលរួមចំណែកអភិវឌ្ឍមូលធនមនុស្សប្រកបដោយសក្តានុពលឈានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និងឆ្នាំ២០៥០ខាងមុខ ព្រមទាំងស្របជាមួយកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៤។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ស្នើសុំអនុញ្ញាតជាគោលការណ៍ពី ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបានកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធី ដូចខាងក្រោម៖

១. បានកាត់បន្ថយគោលបំណងគោលនយោបាយពីចំនួនពីរ មកនៅត្រឹមចំនួនមួយ គឺ៖ "ធានាឱ្យប្រជាពលរដ្ឋកម្ពុជាគ្រប់រូបទទួលបានការអប់រំប្រកបដោយគុណភាព សមធម៌ និងបរិយាបន្ន ពោរពេញដោយចំណេះដឹង បំណិន វិន័យ សីលធម៌ និងឥរិយាបថល្អ ព្រមទាំងសុខភាពល្អ កាយសម្បទារឹងមាំ និងការសិក្សាពេញមួយជីវិត"។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

២. បានរក្សាទុកកម្មវិធីនៅចំនួន០៥ ដដែល ដោយបានកែសម្រួលខ្លឹមសារនៃកម្មវិធីឱ្យមានលក្ខណៈប្រសើរជាងមុនឱ្យស្របជាមួយនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ។ ក្នុងន័យនេះ បានកាត់បន្ថយចំនួនអនុកម្មវិធីពីចំនួន៥៨ មកត្រឹម១៨ និងចង្កោមសកម្មភាពពីចំនួន២០៨ មកត្រឹម៥៨ ក្នុងគោលបំណងពង្រឹងគុណភាពនៃការរៀបចំថវិកាឱ្យប្រកបដោយស័ក្តិសិទ្ធិភាព និងប្រសិទ្ធភាព នឹងឆ្លើយតបការរៀបចំថវិកាសមិទ្ធកម្ម។

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| **កម្មវិធីទី១៖ ការអប់រំកុមារតូច និងចំណេះទូទៅ** | | | | | | |
| | ១.១ | ការអប់រំកុមារតូចបឋមសិក្សា | | | | |
| | | | ១.១.១ | ការគាំពារនិងការអភិវឌ្ឍកុមារតូច | នាយកដ្ឋានអប់រំកុមារតូច | |
| | | | ១.១.២ | ការលើកកម្ពស់នៃការរៀនសូត្រនៅបឋមសិក្សា | នាយកដ្ឋានបឋមសិក្សា | |
| | ១.២ | ការអប់រំមធ្យមសិក្សាចំណេះទូទៅ និងការអប់រំបច្ចេកទេស | | | | |
| | | | ១.២.១ | ការលើកកម្ពស់នៃការរៀនសូត្រនៅមធ្យមសិក្សា | នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ | |
| | | | ១.២.២ | ការលើកកម្ពស់ការអប់រំតម្រង់ទិសវិជ្ជាជីវៈ | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | |
| | ១.៣ | ការអប់រំក្រៅប្រព័ន្ធនិងបរិយាបន្ន | | | | |
| | | | ១.៣.១ | ការអប់រំក្រៅប្រព័ន្ធ | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន | |
| | | | ១.៣.២ | ការអប់រំបរិយាបន្ន | នាយកដ្ឋានអប់រំក្រៅប្រព័ន្ធ និងបរិយាបន្ន | |

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | ១.៤ | ការអភិវឌ្ឍកម្មវិធីសិក្សា និងសុខភាពសិក្សា | | | | |
| | | | ១.៤.១ | ការលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា | នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | |
| | | | ១.៤.២ | ការលើកកម្ពស់សុខភាពសិក្សានៅតាមគ្រឹះស្ថានសិក្សា | នាយកដ្ឋានសុខភាពសិក្សា | |
| | ១.៥ | សេវាគាំទ្រការអប់រំកុមារតូចនិងចំណេះទូទៅរបស់មន្ទីរជំនាញរាជធានី ខេត្ត | | ការគាំទ្រការអប់រំកុមារតូចនិងចំណេះទូទៅរបស់មន្ទីរអប់រំ យុវជន និងកីឡា ទាំង ២៥ រាជធានី ខេត្ត | អគ្គលេខាធិការដ្ឋាន | ២៥ ចង្កោមសកម្មភាព |
| **កម្មវិធីទី២៖ ការអប់រំឧត្តមសិក្សា៖** | | | | | | |
| | ២.១ | ការគ្រប់គ្រងការអប់រំនិងការស្រាវជ្រាវនៅឧត្តមសិក្សា | | | | |
| | | | ២.១.១ | ការលើកកម្ពស់គុណភាពនិងភាពឆ្លើយតបនៃការអប់រំនៅឧត្តមសិក្សា | នាយកដ្ឋានគ្រប់គ្រងឧត្តមសិក្សា | |
| | | | ២.១.២ | ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលថ្នាក់ក្រោយបរិញ្ញាបត្រនិងជំរុញការស្រាវជ្រាវនៅឧត្តមសិក្សា | នាយកដ្ឋានស្រាវជ្រាវនិងនវានុវត្តន៍ | |
| | | | ២.១.៣ | ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា | គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា | |
| | ២.២ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅ | | | | |

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | តាមគ្រឹះស្ថានឧត្តមសិក្សា | | | | |
| | | | ២.២.១ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | |
| | | | ២.២.២ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅសាកលវិទ្យាល័យហេងសំរិនត្បូងឃ្មុំ | សាកលវិទ្យាល័យហេងសំរិនត្បូងឃ្មុំ | |
| | | | ២.២.៣ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅសាកលវិទ្យាល័យជាតិ ជាស៊ីម កំចាយមារ | សាកលវិទ្យាល័យជាតិ ជា ស៊ីម កំចាយមារ | |
| | | | ២.២.៤ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | |
| | | | ២.២.៥ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅសាកលវិទ្យាល័យស្វាយរៀង | សាកលវិទ្យាល័យស្វាយរៀង | |
| | | | ២.២.៦ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅសាកលវិទ្យាល័យជាតិមានជ័យ | សាកលវិទ្យាល័យជាតិមានជ័យ | |
| | | | ២.២.៧ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅសាកលវិទ្យាល័យជាតិបាត់ដំបង | សាកលវិទ្យាល័យជាតិបាត់ដំបង | |
| | | | ២.២.៨ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | |
| | | | ២.២.៩ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅសាកលវិទ្យាល័យក្រចេះ | សាកលវិទ្យាល័យក្រចេះ | |

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ២.២.១០ | ការអភិវឌ្ឍការអប់រំនិងការស្រាវជ្រាវនៅវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | |
| | | | ២.២.១១ | ការអភិវឌ្ឍការអប់រំ និងការស្រាវជ្រាវនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច | |
| | | | ២.២.១២ | ការអភិវឌ្ឍការអប់រំ និងការស្រាវជ្រាវនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង | សាកលវិទ្យាល័យជាតិគ្រប់គ្រង | |
| **កម្មវិធីទី៣៖ ការអប់រំកាយ និងកីឡា៖** | | | | | | |
| | ៣.១ | ការលើកកម្ពស់ការអប់រំកាយហាត់ប្រាណ និងលេងកីឡា | | | | |
| | | | ៣.១.១ | ការអភិវឌ្ឍកីឡាជំនាញ និងកីឡាមហាជន | នាយកដ្ឋានកីឡាជំនាញនិងកីឡាមហាជន | |
| | | | ៣.១.២ | ការអប់រំកាយនិងកីឡាសិស្ស និស្សិត | នាយកដ្ឋានអប់រំកាយនិងកីឡាសិស្សនិស្សិត | |
| | | | ៣.១.៣ | ការបណ្តុះបណ្តាលធនធានមនុស្សផ្នែកអប់រំកាយនិងកីឡា | វិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | |
| | ៣.២ | ការលើកកម្ពស់គុណភាពកីឡា | | | | |
| | | | ៣.២.១ | ការអភិវឌ្ឍកីឡាកម្រិតខ្ពស់ | មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | |
| | | | ៣.២.២ | ការរៀបចំព្រឹត្តិការណ៍កីឡាគ្រប់កម្រិតនិងការចងក្រង | នាយកដ្ឋាន | |

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | ស្ថិតិកីឡា | រៀបចំព្រឹត្តិការណ៍ និងស្ថិតិកីឡា | |
| | | | ៣.២.៣ | ការគ្រប់គ្រងបច្ចេកទេសទីលានកីឡា | ពហុកីឡដ្ឋានជាតិ | |
| | ៣.៣ | សេវាគាំទ្រការអប់រំកាយ និងកីឡារបស់មន្ទីរជំនាញរាជធានី ខេត្ត | | ការគាំទ្រការអប់រំកាយ និងកីឡារបស់មន្ទីរអប់រំ យុវជន និងកីឡាទាំង២៥ រាជធានី ខេត្ត | អគ្គលេខាធិការដ្ឋាន | ២៥ ចង្កោមសកម្មភាព |
| **កម្មវិធីទី៤៖ ការអភិវឌ្ឍយុវជន** | | | | | | |
| | ៤.១ | ការអភិវឌ្ឍសមត្ថភាពយុវជន | | | | |
| | | | ៤.១.១ | ការអប់រំយុវជននិងកុមារ | នាយកដ្ឋានអប់រំយុវជន និងកុមារ | |
| | | | ៤.១.២ | ការលើកកម្ពស់សមត្ថភាពយុវជន | នាយកដ្ឋានអភិវឌ្ឍកម្មវិធីយុវជន | |
| | ៤.២ | ការអភិវឌ្ឍកាយរឹទ្ធិកម្ម | | | | |
| | | | ៤.២.១ | ការអប់រំកាយរឹទ្ធិកម្មតាមគ្រឹះស្ថានសិក្សា | នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ | |
| | | | ៤.២.២ | ការអប់រំកាយរឹទ្ធិកម្មតាមសហគមន៍ | នាយកដ្ឋានសហប្រតិបត្តិការកាយរឹទ្ធិ | |
| | ៤.៣ | សេវាគាំទ្រការអភិវឌ្ឍយុវជនរបស់មន្ទីរជំនាញរាជធានី ខេត្ត | | ការគាំទ្រការអភិវឌ្ឍយុវជនរបស់មន្ទីរអប់រំ យុវជន និងកីឡាទាំង២៥ រាជធានី ខេត្ត | អគ្គលេខាធិការដ្ឋាន | ២៥ ចង្កោមសកម្មភាព |
| **កម្មវិធីទី៥៖ ការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅ** | | | | | | |
| | ៥.១ | ការអភិវឌ្ឍគោលនយោបាយ និងផែនការអប់រំ | | | | |

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ៥.១.១ | ការរៀបចំគោលនយោបាយអប់រំ | នាយកដ្ឋានគោលនយោបាយ | |
| | | | ៥.១.២ | ការរៀបចំផែនការអប់រំផ្តោតលើលទ្ធផល | នាយកដ្ឋានផែនការ | |
| | | | ៥.១.៣ | ការអភិវឌ្ឍប្រព័ន្ធស្ថិតិអប់រំ | នាយកដ្ឋានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ | |
| | ៥.២ | ការគ្រប់គ្រងរដ្ឋបាល ធនធានមនុស្ស ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិរដ្ឋនិងការគាំទ្រសេវាអប់រំ | | | | |
| | | | ៥.២.១ | សេវារដ្ឋបាល | នាយកដ្ឋានរដ្ឋបាល | |
| | | | ៥.២.២ | ការគ្រប់គ្រងធនធានមនុស្ស | នាយកដ្ឋានធនធានមនុស្ស | |
| | | | ៥.២.៣ | ការគ្រប់គ្រងហិរញ្ញវត្ថុ | នាយកដ្ឋានហិរញ្ញវត្ថុ | |
| | | | ៥.២.៤ | ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងហេដ្ឋារចនាសម្ព័ន្ធអប់រំ | នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងសំណង់ | |
| | | | ៥.២.៥ | កិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិ | នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងកិច្ចការអាស៊ាន | |
| | | | ៥.២.៦ | ការគ្រប់គ្រងបរិវត្តកម្មឌីជីថល | នាយកដ្ឋានបរិវត្តកម្មឌីជីថល | |
| | | | ៥.២.៧ | ការពិនិត្យតាមដាន និងវាយតម្លៃ | នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ | |

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ៥.២.៨ | ការងារនីតិកម្ម និងវិមជ្ឈការ និងវិសហមជ្ឈការ | នាយកដ្ឋាននីតិកម្ម | |
| | | | ៥.២.៩ | កិច្ចការប្រឡង | នាយកដ្ឋានកិច្ចការប្រឡង | |
| | ៥.៣ | ការងារបណ្តុះបណ្តាលនិងវិក្រឹតការ | | | | |
| | | | ៥.៣.១ | ការគ្រប់គ្រងកិច្ចការបណ្តុះបណ្តាល | នាយកដ្ឋានកិច្ចការបណ្តុះបណ្តាល | |
| | | | ៥.៣.២ | ការគ្រប់គ្រងកិច្ចការវិក្រឹតការ | នាយកដ្ឋានកិច្ចការវិក្រឹតការ | |
| | | | ៥.៣.៣ | ការបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតឧត្តម មន្រ្តីគ្រប់គ្រងអប់រំ និងការស្រាវជ្រាវអប់រំ | វិទ្យាស្ថានជាតិអប់រំ | |
| | | | ៥.៣.៤ | ការងារបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋម និងកម្រិតមូលដ្ឋាន និងការស្រាវជ្រាវប្រតិបត្តិ (ភ្នំពេញ) | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | |
| | | | ៥.៣.៥ | ការងារបណ្តុះបណ្តាលគ្រូបង្រៀនកម្រិតបឋម និងកម្រិតមូលដ្ឋាន និងការស្រាវជ្រាវប្រតិបត្តិ (បាត់ដំបង) | វិទ្យាស្ថានគរុកោសល្យបាត់ដំបង | |
| | ៥.៤ | ការងារអធិការកិច្ចនិងសវនកម្មផ្ទៃក្នុង | | | | |
| | | | ៥.៤.១ | ការងារអធិការកិច្ចលើបណ្តឹងតវ៉ា | នាយកដ្ឋានអធិការកិច្ចនិងបណ្តឹងតវ៉ា | |

| កម្មវិធី | អនុកម្មវិធី | | ចង្កោមសកម្មភាព | | អង្គភាពទទួលបន្ទុក | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | ៥.៤.២ | ការងារអធិការកិច្ចអប់រំ និងវាយតម្លៃគុណភាពអប់រំ | នាយកដ្ឋានអធិការកិច្ចគុណភាពអប់រំ | |
| | | | ៥.៤.៣ | ការធ្វើសវនកម្មផ្ទៃក្នុង | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | |
| | ៥.៥ | សេវាគាំទ្រការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅរបស់មន្ទីរជំនាញ រាជធានី ខេត្ត | | ការគាំទ្រការគ្រប់គ្រងស្ថាប័ន និងសេវាគាំទ្រទូទៅរបស់មន្ទីរអប់រំ យុវជន និងកីឡា ទាំង២៥ រាជធានី ខេត្ត | អគ្គលេខាធិការដ្ឋាន | ២៥ ចង្កោមសកម្មភាព |

សេចក្តីដូចបានគោរពជម្រាបជូនខាងលើ សូម ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីមេត្តាពិនិត្យលទ្ធភាពអនុញ្ញាតជាគោលការណ៍ ឱ្យក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលរចនាសម្ព័ន្ធថវិកាកម្មវិធីសម្រាប់ការអនុវត្តចាប់ពីឆ្នាំ២០២៦ តទៅ ដោយសេចក្តីអនុគ្រោះ។

សូម ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មេត្តាទទួលនូវគារវកិច្ចដ៏ស្មោះពីខ្ញុំ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គលេខាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានហិរញ្ញវត្ថុ